# កិច្ចព្រមព្រៀងទីក្រុងឡូកាណូ
# ការបង្កើតចំណាត់ថ្នាក់អន្តរជាតិចំពោះគំនូរឧស្សាហកម្ម

## បានចុះហត្ថលេខានៅទីក្រុងឡូកាណូនៅថ្ងៃទី៨ ខែតុលា ឆ្នាំ១៩៦៨
## ដូចបានធ្វើវិសោធនកម្មនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៧៩

## មាត្រា១
## ការបង្កើតសហភាពពិសេស ការអនុម័តចំណាត់ថ្នាក់អន្តរជាតិ

១- ប្រទេសដែលអនុវត្តកិច្ចព្រមព្រៀងនេះបង្កើតជាសហភាពពិសេសមួយ ។

២-ប្រទេសទាំងនេះអនុម័តចំណាត់ថ្នាក់តែមួយចំពោះគំនូរឧស្សាហកម្ម ( តទៅហៅថា “ចំណាត់ថ្នាក់អន្តរជាតិ” ) ។

៣- ចំណាត់ថ្នាក់អន្តរជាតិត្រូវរួមមាន:

- (i) បញ្ជីនៃក្រុម និងអនុក្រុម
- (ii) បញ្ជីទំនិញតាមអក្ខរក្រមដែលមានបញ្ចូលគំនូរឧស្សាហកម្ម ដោយមានការបង្ហាញអំពីក្រុមនិងអនុក្រុម
- (iii) កំណត់ពន្យល់ ។

៤- បញ្ជីនៃក្រុម និងអនុក្រុម គឺជាបញ្ជីដែលភ្ជាប់ក្នុងឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះដែលជាកម្មវត្ថុនៃវិសោធនកម្មនិងការបន្ថែម ដូចដែលគណៈកម្មាធិការជំនាញ ដែលបានបង្កើតតាមមាត្រា៣ (តទៅហៅថា “គណៈកម្មាធិការជំនាញ ” ) អាចធ្វើវិសោធនកម្មនិងបន្ថែម ចំពោះបញ្ជីនេះ ។

៥- បញ្ជីទំនិញតាមអក្ខរក្រម និងកំណត់ពន្យល់ ត្រូវអនុម័តដោយគណៈកម្មាធិការជំនាញស្របតាមនីតិវិធីដែលបានកំណត់ក្នុងមាត្រា៣ ។

៦- អនុលោមតាមតាមនីតិវិធីដែលបានកំណត់ក្នុងមាត្រា៣ គណៈកម្មាធិការជំនាញអាចធ្វើវិសោធនកម្ម ឬបំពេញបន្ថែមចំពោះចំណាត់ថ្នាក់អន្តរជាតិ ។

៧-

ក- ចំណាត់ថ្នាក់អន្តរជាតិត្រូវធ្វើជាភាសាអង់គ្លេស និងភាសាបារាំង ។

ខ- អត្ថបទផ្លូវការនៃចំណាត់ថ្នាក់អន្តរជាតិ ជាភាសាផ្សេងទៀតដែលសន្និបាតបានកំណត់ដូចមានចែងក្នុងមាត្រា៥ ត្រូវធ្វើឡើងដោយការិយាល័យកម្មសិទ្ធិបញ្ញាអន្តរជាតិ (តទៅហៅថា“ការិយាល័យអន្តរជាតិ”) បន្ទាប់ពីការប្រឹក្សាយោបល់ជាមួយរដ្ឋាភិបាលពាក់ព័ន្ធ ដូចមានចែងក្នុងអនុសញ្ញាស្តីការបង្កើតអង្គការកម្មសិទ្ធិបញ្ញាពិភពលោក(តទៅហៅថា“អង្គការ”) ។

## មាត្រា២
## ការប្រើប្រាស់ និងវិសាលភាពផ្លូវច្បាប់នៃចំណាត់ថ្នាក់អន្តរជាតិ

១- លើកលែងលក្ខខណ្ឌដែលបានកំណត់ដោយកិច្ចព្រមព្រៀងនេះ ចំណាត់ថ្នាក់អន្តរជាតិត្រូវមានចារិកលក្ខណៈបែបរដ្ឋបាលប៉ុណ្ណោះ ។ ប៉ុន្តែ ប្រទេសនីមួយៗអាចកំណត់វិសាលភាពផ្លូវច្បាប់ចំពោះ ចំណាត់ថ្នាក់អន្តរជាតិដែលខ្លួនគិតថាត្រឹមត្រូវ ។ ដោយឡែក ចំណាត់ថ្នាក់អន្តរជាតិមិនត្រូវចងភ្ជាប់ប្រទេសទាំងឡាយក្នុងសហភាពពិសេសទាក់ទងនឹងលក្ខណៈ និងវិសាលភាពនៃកិច្ចការពារដែលបានផ្តល់ឱ្យគំនូរនៅក្នុងប្រទេសទាំងនេះ ។
២- ប្រទេសនីមួយៗក្នុងសហភាពពិសេសរក្សាសិទ្ធិក្នុងការប្រើប្រាស់ចំណាត់ថ្នាក់អន្តរជាតិជាប្រព័ន្ធគោល ឬជាប្រព័ន្ធជំនួយ ។
៣- ការិយាល័យរបស់ប្រទេសទាំងឡាយក្នុងសហភាពពិសេស ត្រូវបញ្ចូលក្នុងឯកសារផ្លូវការចំពោះការតម្កល់ ឬការចុះបញ្ជីគំនូរ ហើយ ប្រសិនបើការតម្កល់ ឬការចុះបញ្ជីត្រូវបានបោះពុម្ពផ្សាយជាផ្លូវការ ត្រូវបញ្ចូលក្នុងការបោះពុម្ពផ្សាយនោះនូវចំនួននៃក្រុម និងអនុក្រុមនៃចំណាត់ថ្នាក់អន្តរជាតិរបស់ទំនិញដែលបំពាក់គំនូរ ។
៤- ក្នុងការជ្រើសរើសពាក្យដើម្បីបញ្ចូលក្នុងបញ្ជីទំនិញតាមអក្ខរក្រម គណៈកម្មាធិការជំនាញត្រូវអនុវត្តដោយយកចិត្តទុកដាក់ដើម្បីជៀសវាងការប្រើប្រាស់ពាក្យដែលអាច កើតមាននូវសិទ្ធិផ្តាច់មុខ ។ ប៉ុន្តែ ការបញ្ចូលពាក្យណាមួយក្នុងតារាងតាមអក្ខរក្រមមិនមែនជាការបង្ហាញគំនិតរបស់គណៈកម្មាធិការជំនាញថាតើពាក្យនេះពាក់ព័ន្ធ ឬមិនពាក់ព័ន្ធនឹងសិទ្ធិផ្តាច់មុខ ។

## មាត្រា៣
## គណៈកម្មាធិការជំនាញ

១- គណៈកម្មាធិការជំនាញត្រូវទទួលខុសត្រូវកិច្ចការទាំងឡាយដូចមានចែងក្នុងមាត្រា ១(៤)

មាត្រា១(៥)និងមាត្រា១(៦) ។ ប្រទេសនីមួយៗក្នុងសហភាពពិសេស ត្រូវមានតំណាងក្នុងគណៈកម្មាធិការជំនាញ ដែលត្រូវបានចាត់តាំងតាមបទបញ្ជាផ្ទៃក្នុងដែល បានអនុម័តដោយសំលេងភាគច្រើនធម្មតានៃប្រទេសទាំងឡាយដែលជាតំណាង ។

២- គណៈកម្មាធិការជំនាញត្រូវអនុម័តបញ្ជីតាមអក្ខរក្រម និងកំណត់ពន្យល់ដោយសំលេងភាគច្រើនធម្មតានៃសំលេងឆ្នោតរបស់ប្រទេសទាំងឡាយក្នុងសហភាពពិសេស ។

៣- សំណើធ្វើវិសោធនកម្ម ឬបន្ថែមចំពោះចំណាត់ថ្នាក់អន្តរជាតិអាចធ្វើឡើងដោយការិយាល័យរបស់ប្រទេសណាមួយក្នុងសហភាពពិសេសឬដោយការិយាល័យអន្តរជាតិ ។ សំណើណាមួយចេញពីការិយាល័យ ត្រូវជូនដំណឹងដោយការិយាល័យនេះ ទៅការិយាល័យអន្តរជាតិ ។ សំណើដែលចេញពីការិយាល័យនិងពីការិយាល័យអន្តរជាតិ ការិយាល័យអន្តរជាតិត្រូវបញ្ជូនទៅកាន់សមាជិកនៃគណៈកម្មាធិការជំនាញដោយមិនឱ្យលើសពីពីរ(២)ខែ មុនសម័យប្រជុំរបស់គណៈកម្មាធិការជំនាញដើម្បីយកសំណើនេះមកពិចារណា ។

៤- សេចក្តីសម្រេចរបស់គណៈកម្មាធិការជំនាញពាក់ព័ន្ធនឹងការអនុម័តវិសោធនកម្ម និងការបន្ថែមដែលបានធ្វើឡើងចំពោះចំណាត់ថ្នាក់អន្តរជាតិត្រូវមានសំលេងភាគច្រើនធម្មតានៃប្រទេសទាំងឡាយក្នុងសហភាពពិសេស ។ ប៉ុន្តែ ត្រូវទាមទារឱ្យមានសំលេងឯកច្ឆន្ទប្រសិនបើសេចក្តីសម្រេចនេះពាក់ព័ន្ធនឹងការបង្កើតក្រុមថ្មី ឬការផ្ទេរទំនិញពីក្រុមមួយទៅក្រុមផ្សេងទៀត ។

៥- អ្នកជំនាញម្នាក់ៗត្រូវមានសិទ្ធិបោះឆ្នោតពីចំងាយ ។

៦- ប្រសិនបើប្រទេសមួយមិនបានចាត់តាំងអ្នកតំណាងសម្រាប់សម័យប្រជុំណាមួយរបស់គណៈកម្មាធិការជំនាញ ឬប្រសិនបើអ្នកជំនាញដែលបានចាត់តាំងមិនបានបោះឆ្នោតរបស់ខ្លួនក្នុងអំឡុងសម័យប្រជុំ ឬក្នុងរយៈពេលដែលបានកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មាធិការជំនាញ ប្រទេសដែលពាក់ព័ន្ធត្រូវចាត់ទុកថាបានទទួលយកសេចក្តីសម្រេចរបស់គណៈកម្មាធិការ ។

## មាត្រា៤
## សេចក្តីជូនដំណឹង និងការបោះពុម្ពផ្សាយអំពីចំណាត់ថ្នាក់ និង អំពីវិសោធនកម្មនិង ការបន្ថែមលើចំណាត់ថ្នាក់

១- បញ្ជីទំនិញតាមអក្ខរក្រម និងកំណត់ពន្យល់ដែលបានអនុម័តដោយគណៈកម្មាធិការជំនាញ ក៏ដូចជាវិសោធនកម្មឬការបន្ថែមណាមួយចំពោះចំណាត់ថ្នាក់អន្តរជាតិដែលបានសម្រេចដោយគណៈកម្មាធិការ ការិយាល័យអន្តរជាតិត្រូវជូនដំណឹងទៅកាន់ការិយាល័យរបស់ប្រទេសទាំងឡាយក្នុងសហភាពពិសេស។ សេចក្តី សម្រេចរបស់គណៈកម្មាធិការជំនាញ ត្រូវចូលជាធរមានភ្លាមនៅពេលបានទទួលការជូនដំណឹង ។ ប៉ុន្តែ ប្រសិនបើសេចក្តីសម្រេចនេះពាក់ព័ន្ធនឹងការបង្កើតក្រុមថ្មី ឬការផ្ទេរទំនិញពីក្រុមមួយទៅក្រុមផ្សេងទៀត សេចក្តីសម្រេចនេះ ត្រូវចូលជាធរមានក្នុងរយៈពេល៦(ប្រាំមួយ)ខែ ចាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងនេះ ។

២- ការិយាល័យអន្តរជាតិដែលជាកន្លែងតម្កល់នៃចំណាត់ថ្នាក់អន្តរជាតិ ត្រូវបញ្ចូលក្នុងចំណាត់ថ្នាក់អន្តរជាតិនូវវិសោធនកម្មនិងការបន្ថែមដែលបានចូលជាធរមាន ។ សេចក្តីជូនដំណឹងអំពីវិសោធនកម្មនិងការបន្ថែមត្រូវបោះពុម្ពផ្សាយក្នុងព្រឹត្តិបត្រដែល ត្រូវកំណត់ដោយសន្និបាត ។

## មាត្រា៥
## សន្និបាតនៃសហភាពពិសេស

១-

ក- សហភាពពិសេសត្រូវមានសន្និបាតមួយ ដែលរួមមានប្រទេសទាំងឡាយនៃសហភាពពិសេស ។

ខ- រដ្ឋាភិបាលរបស់ប្រទេសនីមួយៗនៃសហភាពពិសេស ត្រូវតំណាងដោយប្រតិភូមួយរូប ដែល អាចអមដោយប្រតិភូស្តីទី ទីប្រឹក្សា និងអ្នកជំនាញមួយចំនួន ។

គ- ការចំណាយរបស់គណៈប្រតិភូនីមួយៗ ជាបន្ទុករបស់រដ្ឋាភិបាលដែលតែងតាំងគណៈប្រតិភូនេះ ។

២-

ក- លើកលែងបទប្បញ្ញត្តិនៃមាត្រា៣ សន្និបាតត្រូវៈ

(i) ពិភាក្សារាល់បញ្ហាទាំងអស់ដែលទាក់ទងនឹងការរក្សានិងការអភិវឌ្ឍន៍នៃសហភាពពិសេស និងការអនុវត្តន៍កិច្ចព្រមព្រៀងនេះ ។

(ii) ណែនាំការិយាល័យអន្តរជាតិអំពីការរៀបចំសន្និសីទកែប្រែ ។

(iii) ត្រួតពិនិត្យ និងអនុម័តរបាយការណ៍ និងសកម្មភាពរបស់អគ្គនាយកនៃអង្គការ (តទៅហៅថា "អគ្គនាយក" ) ដែលទាក់ទងនឹងសហភាពពិសេស ហើយណែនាំតាមការចាំបាច់ដល់អគ្គនាយក ទាក់ទងនឹងបញ្ហានៃសមត្ថកិច្ចរបស់សហភាពពិសេស ។

(iv) កំណត់កម្មវិធី និងអនុម័តថវិកាពីរឆ្នាំម្តងនៃសហភាពពិសេស និងអនុម័តការបិទបញ្ជីគណនី ។

(v) អនុម័តបទបញ្ជាស្តីពីហិរញ្ញវត្ថុរបស់សហភាពពិសេស ។

(vi) សម្រេចលើការបង្កើតអត្ថបទផ្លូវការនៃចំណាត់ថ្នាក់អន្តរជាតិជាភាសានានាក្រៅពី ភាសាអង់គ្លេស និងភាសាបារាំង ។

(vii) បន្ថែមលើគណៈកម្មាធិការជំនាញដូចមានចែងក្នុងមាត្រា៣ បង្កើតគណៈកម្មាធិការជំនាញផ្សេងទៀត និងក្រុមការងារដែលចាំបាច់ដើម្បីសម្រេចគោលបំណងរបស់សហភាពពិសេស ។

(viii) កំណត់ឱ្យចូលរួមក្នុងកិច្ចប្រជុំ ក្នុងឋានៈជាអ្នកសង្កេតការណ៍ចំពោះប្រទេសដែលមិនមែនជាសមាជិកនៃសហភាពពិសេស និងអង្គការអន្តររដ្ឋាភិបាលនិងអង្គការអន្តរជាតិមិនមែនរដ្ឋាភិបាល ។

(ix) អនុម័តវិសោធនកម្មមាត្រា៥ ដល់ មាត្រា៨ ។

(x) ចាត់វិធានការសមស្របផ្សេងទៀតដើម្បីសម្រេចគោលបំណងរបស់សហភាពពិសេស ។

(xi) បំពេញមុខងារផ្សេងទៀតដែលស្របតាមកិច្ចព្រមព្រៀងនេះ ។

ខ- ចំពោះបញ្ហាដែលពាក់ព័ន្ធនឹងផលប្រយោជន៍ផងដែរ របស់សហភាពផ្សេងទៀតដែលគ្រប់គ្រងដោយអង្គការ សន្និបាតត្រូវធ្វើការសម្រេច បន្ទាប់ពីបានស្តាប់យោបល់របស់គណៈកម្មាធិការសម្របសម្រួលនៃអង្គការ ។

៣-

ក- ប្រទេសនីមួយៗជាសមាជិកនៃសន្និបាតមានសំលេងឆ្នោតតែមួយ ។

ខ- កូរ៉ុមនៃសន្និបាតត្រូវមានចំនួនពាក់កណ្តាលនៃប្រទេសជាសមាជិក ។

គ- ថ្វីបើមានចែងក្នុងបទប្បញ្ញត្តិនៃអនុកថាខណ្ឌ(ខ)ក៏ដោយ ក្នុងសម័យប្រជុំនីមួយ ៗ ប្រសិនបើចំនួនប្រទេសតំណាងមានតិចជាងមួយភាគពីរ(១/២) ប៉ុន្តែ ស្មើឬច្រើនជាងមួយភាគបី(១/៣)នៃប្រទេសជាសមាជិកទាំងឡាយនៃសន្និបាត សន្និបាតអាចធ្វើសេចក្តីសម្រេចបាន ប៉ុន្តែសេចក្តីសម្រេចទាំងនេះ ត្រូវយកមកអនុវត្តបានតែក្នុងករណីបានបំពេញលក្ខខណ្ឌកំណត់ដូចខាងក្រោម លើកលែងតែសេចក្តីសម្រេចនោះទាក់ទងជាមួយនីតិវិធីរបស់សន្និបាតផ្ទាល់ ។ ការិយាល័យអន្តរជាតិត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនេះ ទៅប្រទេសសមាជិកសន្និបាតទាំងឡាយដែលគ្មានតំណាង និងត្រូវអញ្ជើញប្រទេសទាំងនេះឱ្យបោះឆ្នោតជាលាយលក្ខណ៍អក្សរ ឬបោះឆ្នោតអនុប្បវាទ ក្នុងរយៈពេលបី(៣)ខែ ចាប់ពីថ្ងៃជូនដំណឹង ។ បើផុតរយៈពេលនេះ ប្រសិនបើចំនួននៃប្រទេសដែលបានបោះឆ្នោតឬបោះឆ្នោតអនុប្បវាទ ស្មើនឹងចំនួនដែលខ្វះសម្រាប់កូរ៉ុមក្នុងសម័យប្រជុំ សេចក្តីសម្រេចនេះនឹងអាចយកមកអនុវត្តបាន ឱ្យតែបានគ្រប់សំលេងភាគច្រើនដែលត្រូវការ ។

ឃ- លើកលែងតែបទប្បញ្ញត្តិនៃមាត្រា៨(២) សេចក្តីសម្រេចនៃសន្និបាតតម្រូវឱ្យមានសំលេង២/៣(ពីរភាគបី) នៃសំលេងឆ្នោតដែលបានបោះ ។

ង- អនុប្បវាទមិនត្រូវចាត់ទុកជាសំលេងឆ្នោតទេ ។

ច- ប្រតិភូម្នាក់អាចតំណាង ហើយបោះឆ្នោតបានក្នុងនាមប្រទេសតែមួយគត់ ។

៤-

ក- សន្និបាតត្រូវប្រជុំជាសាមញ្ញរៀងរាល់ពីរឆ្នាំម្តង តាមការកោះប្រជុំរបស់អគ្គនាយក ហើយបើគ្មានករណីពិសេស ត្រូវប្រជុំក្នុងពេលនិងកន្លែងដូចគ្នានឹងមហាសន្និបាតរបស់អង្គការ ។

ខ- តាមសំណើសុំពីប្រទេសជាសមាជិកសន្និបាតចំនួនមួយភាគបួន(១/៤) សន្និបាតត្រូវប្រជុំជាវិសាមញ្ញបាន តាមការកោះប្រជុំរបស់អគ្គនាយក ។

គ- របៀបវារៈនៃការប្រជុំនីមួយៗត្រូវរៀបចំដោយអគ្គនាយក ។

៥- សន្និបាតត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

## មាត្រា៦
## ការិយាល័យអន្តរជាតិ

១-

ក- ការងាររដ្ឋបាលទាំងឡាយដែលទាក់ទងនឹងសហភាពពិសេសត្រូវបំពេញដោយការិយាល័យអន្តរជាតិ ។

ខ- ជាពិសេស ការិយាល័យអន្តរជាតិត្រូវរៀបចំកិច្ចប្រជុំ និងត្រូវបំរើការងារជាលេខាធិការដ្ឋានសម្រាប់សន្និបាត សម្រាប់គណៈកម្មាធិការជំនាញ និងសម្រាប់គណៈកម្មាធិការជំនាញផ្សេងទៀត និងក្រុមការងារដែលអាចនឹងបង្កើតឡើងដោយសន្និបាត ឬគណៈកម្មាធិការជំនាញ ។

គ- អគ្គនាយកត្រូវជានាយកប្រតិបត្តិនៃសហភាពពិសេសនិងត្រូវតំណាងឱ្យសហភាពពិសេស ។

២- អគ្គនាយក និងបុគ្គលិកណាម្នាក់ដែលត្រូវចាត់តាំងដោយអគ្គនាយក ត្រូវចូលរួមរាល់កិច្ចប្រជុំរបស់សន្និបាត របស់គណៈកម្មាធិការជំនាញ និងរបស់គណៈកម្មាធិការជំនាញផ្សេងទៀត ឬក្រុមការងារដែលនឹងអាចបង្កើតឡើងដោយសន្និបាត ឬគណៈកម្មាធិការជំនាញតែគ្មានសិទ្ធិបោះឆ្នោតទេ ។ អគ្គនាយក ឬ បុគ្គលិកណាម្នាក់ដែលត្រូវចាត់តាំងដោយអគ្គនាយក គឺជាលេខាដោយស្វ័យប្រវត្តិរបស់អង្គភាពទាំងនោះ ។

៣-

ក- ស្របតាមសេចក្តីណែនាំរបស់សន្និបាត ការិយាល័យអន្តរជាតិត្រូវរៀបចំសន្និសីទកែប្រែបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ លើកលែងមាត្រា៥ ដល់មាត្រា៨ ។

ខ- ការិយាល័យអន្តរជាតិអាចប្រឹក្សាជាមួយអង្គការអន្តររដ្ឋាភិបាល និងអង្គការអន្តរជាតិមិនមែនរដ្ឋាភិបាលពាក់ព័ន្ធនឹងការរៀបចំសន្និសីទកែប្រែនេះ ។

គ-អគ្គនាយកនិងបុគ្គលដែលត្រូវចាត់តាំងដោយអគ្គនាយក ត្រូវចូលរួមក្នុងកិច្ចពិភាក្សាក្នុងសន្និសីទទាំងនោះ តែគ្មានសិទ្ធិបោះឆ្នោតទេ ។

៤- ការិយាល័យអន្តរជាតិត្រូវអនុវត្តការងារផ្សេងៗទៀតដែលបានប្រគល់ឱ្យ ។

# មាត្រា៧
## ហិរញ្ញវត្ថុ

១-

ក- សហភាពត្រូវមានថវិការបស់ខ្លួន ។

ខ- ថវិការបស់សហភាពពិសេសរួមមានខ្ទង់ចំនូលនិងខ្ទង់ចំណាយផ្ទាល់របស់សហភាពពិសេស វិភាគទានចំពោះថវិកាសម្រាប់ការចំណាយរួមរបស់សហភាព និងបើមានចំនួនទឹកប្រាក់ ដែលមានក្នុងថវិកានៃសន្និសីទរបស់អង្គការ ។

គ- ការចំណាយដែលមិនមែនជាចំណាយផ្តាច់មុខរបស់សហភាពពិសេសប៉ុន្តែជាការចំណាយរបស់សហភាពមួយឬច្រើនផ្សេងទៀត ដែលស្ថិតក្រោមការគ្រប់គ្រងរបស់អង្គការ ត្រូវចាត់ទុកជាចំណាយរួមរបស់សហភាព ។ ចំណែកនៃសហភាពពិសេសក្នុងខ្ទង់ចំណាយរួមនេះ ត្រូវសមាមាត្រនឹងផលប្រយោជន៍ ដែលសហភាពពិសេសទទួលបានក្នុងចំណាយនោះ ។

២- ថវិការបស់សហភាពពិសេសត្រូវបង្កើតឡើងដោយផ្អែកលើតម្រូវការសម្របសម្រួលជាមួយ ថវិកានៃសហភាពផ្សេងទៀតដែលគ្រប់គ្រងដោយអង្គការ ។

៣- ថវិការបស់សហភាពពិសេសទទួលបានពីប្រភពនានាដូចខាងក្រោម:

(i) វិភាគទានពីប្រទេសទាំងឡាយក្នុងសហភាពពិសេស

(ii) កម្រៃ និងថ្លៃឈ្នួលសេវាកម្មដែលផ្តល់ឱ្យដោយការិយាល័យអន្តរជាតិ ទាក់ទងនឹងសហភាពពិសេស

(iii) ការលក់ ឬលាភការ ពីការបោះពុម្ពផ្សាយរបស់ការិយាល័យអន្តរជាតិពាក់ព័ន្ធនឹងសហភាពពិសេស

(iv) អំណោយ អច្ច័យទាន និងឧបត្ថម្ភធន

(v) ការជួល ការប្រាក់ និងចំណូលផ្សេងៗទៀត ។

៤-

ក- ក្នុងគោលបំណងនៃការបង្កើតវិភាគទានដូចមានចែងក្នុងកថាខណ្ឌ(៣)(i) ប្រទេសនីមួយៗនៃសហភាពពិសេស ត្រូវស្ថិតក្នុងថ្នាក់តែមួយដូចថ្នាក់ក្នុងសហភាពទីក្រុងប៉ារីស ស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម ហើយត្រូវបង់វិភាគទានប្រចាំឆ្នាំដោយផ្អែកលើចំនួនតែមួយនៃឯកតាដែលបានកំណត់ចំពោះថ្នាក់ក្នុងសហភាពនេះ ។

ខ- វិភាគទានប្រចាំឆ្នាំនៃប្រទេសនីមួយៗរបស់សហភាពពិសេស ត្រូវមានចំនួនសមាមាត្រដូចគ្នានឹងចំនួនសរុប ដែលបានធ្វើវិភាគទានទៅថវិការបស់សហភាពពិសេសដោយប្រទេសទាំងអស់ដូចនឹងចំនួនឯកតារបស់ខ្លួន ទៅចំនួនសរុបនៃឯកតានៃប្រទេសផ្តល់វិភាគទានទាំងអស់ ។

គ- ការបង់វិភាគទានត្រូវធ្វើឡើងនៅថ្ងៃទី ១ ខែមករា ជារៀងរាល់ឆ្នាំ ។

ឃ- ប្រទេសដែលយឺតយ៉ាវក្នុងការបង់វិភាគទាន មិនអាចអនុវត្តសិទ្ធិបោះឆ្នោតរបស់ខ្លួនក្នុងអង្គភាពណាមួយរបស់សហភាពពិសេសឡើយ ប្រសិនបើចំនួនដែលមិនបានបង់មានចំនួនស្មើឬលើសពីចំនួននៃវិភាគទានត្រូវបង់ចំនួនពីរ(២)ឆ្នាំពេញ។ ប៉ុន្តែ អង្គភាពណាមួយនៃសហភាពអាចអនុញ្ញាតឱ្យប្រទេសដែលយឺតយ៉ាវ អាចបន្តអនុវត្តសិទ្ធិបោះឆ្នោតក្នុងអង្គភាពនោះបាន ដរាបណាបានផ្តល់ហេតុផលថាការយឺតយ៉ាវក្នុងការបង់កម្រៃ បណ្តាលមកពីកាលៈទេសៈពិសេស និងមិនអាចជៀសវាងបាន ។

ង- ប្រសិនបើ ថវិកាមិនត្រូវបានអនុម័តមុនការចាប់ផ្តើមនៃរយៈពេលហិរញ្ញវត្ថុថ្មីទេ ថវិកានោះត្រូវតែចាត់ទុកថាមានកម្រិតស្មើគ្នាទៅនឹងថវិការឆ្នាំមុន ដូចមានចែងក្នុងបទបញ្ជាហិរញ្ញវត្ថុ ។

៥- បរិមាណនៃកម្រៃនិងថ្លៃឈ្នួលសេវាកម្មដែលផ្តល់ឱ្យដោយការិយាល័យអន្តរជាតិពាក់ព័ន្ធនឹងសហភាពពិសេសត្រូវធ្វើឡើង និងត្រូវរាយការណ៍ជូនសន្និបាតដោយអគ្គនាយក ។

៦-

ក- សហភាពពិសេសត្រូវមានមូលនិធិទុនបង្វិលដែលទទួលបាន ពីការបង់ប្រាក់សរុបរួមតែម្តង ពីប្រទេសនីមួយៗនៃសហភាពពិសេស ។ ប្រសិនបើមូលនិធិនេះមិនគ្រប់គ្រាន់ សន្និបាតអាចសម្រេចបង្កើនមូលនិធិនេះបាន ។

ខ- ចំនួននៃការបង់កម្រៃដំបូងរបស់ប្រទេសនីមួយៗក្នុងមូលនិធិនេះ ឬនៃការចូលរួមរបស់ខ្លួនក្នុងការបង្កើនមូលនិធិ ត្រូវសមាមាត្រនឹងវិភាគទាននៃប្រទេសនោះសម្រាប់ឆ្នាំនៃការបង្កើតមូលនិធិនេះ ឬឆ្នាំនៃការសម្រេចបង្កើនមូលនិធិ ។

គ- សមាមាត្រ និងលក្ខខណ្ឌនៃការបង់ប្រាក់ ត្រូវកំណត់ដោយសន្និបាតតាមសំណើរបស់អគ្គនាយក និងបន្ទាប់ពីបានស្តាប់យោបល់របស់គណៈកម្មាធិការសម្របសម្រួលនៃអង្គការ ។

៧-

ក- នៅក្នុងកិច្ចព្រមព្រៀងទីស្នាក់ការដែលបានចុះជាមួយប្រទេស ដែលអង្គការបានដាក់ទីស្នាក់ការ ត្រូវចែងថានៅពេលណាដែលមូនិធិទុនបង្វិលមិនគ្រប់គ្រាន់ ប្រទេសនោះត្រូវបង់ប្រាក់ជាមុន ។ ចំនួននៃប្រាក់បង់ជាមុននិងលក្ខខណ្ឌនៃការបង់ជាមុន ត្រូវកំណត់ដោយកិច្ចព្រមព្រៀង ដោយឡែកពីគ្នារវាងប្រទេសនេះជាមួយអង្គការ ។

ខ- ប្រទេសដូចមានចែងក្នុងអនុកថាខណ្ឌ(ក)និងអង្គការ ត្រូវមានសិទ្ធិបដិសេធកាតព្វកិច្ចបង់ប្រាក់ជាមុន ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរ ។ ការបដិសេធនេះត្រូវមានអានុភាពក្នុង រយៈពេល៣(បី) ឆ្នាំ បន្ទាប់ពីបំណាច់ឆ្នាំនៃការជូនដំណឹង ។

៨- សវនកម្មគណនី ត្រូវធ្វើឡើងដោយប្រទេសមួយ ឬច្រើននៃសហភាពពិសេស ឬដោយសវនករ ខាងក្រៅ ដូចមានចែងក្នុងបទបញ្ញាហិរញ្ញវត្ថុ ហើយត្រូវចាត់តាំងដោយសន្និបាតដោយមានការ យល់ព្រមពីប្រទេសឬសវនករនេះ ។

## មាត្រា៨
## វិសោធនកម្មមាត្រា៥ ដល់មាត្រា៨

១- សំណើសុំវិសោធនកម្មមាត្រា៥ មាត្រា៦ មាត្រា៧និងមាត្រានេះ អាចត្រូវផ្តួចផ្តើមគំនិតដោយប្រទេសណាមួយនៃសហភាពពិសេស ឬដោយអគ្គនាយក ។ សំណើនេះ ត្រូវជូនដំណឹងដោយអគ្គនាយក ទៅប្រទេសទាំងឡាយនៃសហភាពពិសេស យ៉ាងហោចណាស់ក្នុងរយៈពេល៦(ប្រាំមួយ) ខែ មុនពេលសន្និបាតលើកសំណើនេះមកពិចារណា ។

២-វិសោធនកម្មមាត្រាដូចមានចែងក្នុងកថាខណ្ឌទី១ ត្រូវអនុម័តដោយសន្និបាត។ ការអនុម័តនេះទាមទារឱ្យមានសំលេង៣/៤(បីភាគបួន)នៃសំលេងឆ្នោតដែលបានបោះ តែវិសោធនកម្មមាត្រា៥និងកថាខណ្ឌនេះ ទាមទារឱ្យមានសំលេង៤/៥(បួនភាគប្រាំ)នៃសំលេងឆ្នោតដែលបានបោះ ។

៣- វិសោធនកម្មចំពោះមាត្រាណាមួយដូចមានចែងក្នុងកថាខណ្ឌ១ ត្រូវចូលជាធរមានក្នុងរយៈពេល១(មួយ)ខែ បន្ទាប់ពីអគ្គនាយកទទួលបានសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការយល់ព្រម ដែលបានធ្វើឡើងស្របតាមរដ្ឋធម្មនុញ្ញដោយប្រទេស៣/៤(បីភាគបួន) ដែលជាសមាជិករបស់សហភាពពិសេសនៅពេលអនុម័តវិសោធនកម្មនេះ ។ វិសោធនកម្មណាមួយចំពោះមាត្រាទាំងនេះដែលត្រូវបានទទួលយក ត្រូវចងភ្ជាប់ប្រទេសទាំងអស់ដែល

ជាសមាជិកនៃសហភាពពិសេសនៅពេលដែលវិសោធនកម្មចូលជាធរមាន ឬក្លាយជាសមាជិកនាពេលក្រោយ ។ វិសោធនកម្មណាមួយដែលបង្កើនកាតព្វកិច្ចហិរញ្ញវត្ថុរបស់ប្រទេសនៃសហភាពពិសេសត្រូវចងភ្ជាប់តែប្រទេសណាដែលយល់ព្រមចំពោះវិសោធនកម្មនេះប៉ុណ្ណោះ។

## មាត្រា៩
## ការផ្តល់សច្ចាប័ន និងការចូលជាសមាជិក ការចូលជាធរមាន

១- ប្រទេសណាមួយដែលជាភាគីនៃអនុសញ្ញាទីក្រុងប៉ារីសស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្មដែលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ អាចផ្តល់សច្ចាប័នបានហើយ ប្រសិនបើមិនបានចុះហត្ថលេខាទេ អាចចូលជាសមាជិកកិច្ចព្រមព្រៀងនេះ ។
២- លិខិតតុបករណ៍នៃការផ្តល់សច្ចាប័ន និងការចូលជាសមាជិកត្រូវតម្កល់ជូនអគ្គនាយក ។
៣-

ក- កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមានក្នុងរយៈបី(៣)ខែ បន្ទាប់ពីការតម្កល់លិខិតតុបករណ៍ទីប្រាំ ចំពោះប្រាំប្រទេសដំបូងដែលបានតម្កល់លិខិតតុបករណ៍នៃការផ្តល់សច្ចាប័ន ឬការចូលជាសមាជិករបស់ខ្លួន ។

ខ- ចំពោះប្រទេសណាមួយផ្សេងទៀត កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមានក្នុងរយៈពេលបី(៣)ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងអំពីការផ្តល់សច្ចាប័ន ឬការចូលជាសមាជិកដោយអគ្គនាយក លើកលែងតែកាលបរិច្ឆេទបន្ទាប់បានបង្ហាញនៅក្នុងលិខិតតុបករណ៍នៃការផ្តល់សច្ចាប័នឬការចូលជាសមាជិក ។ ក្នុងករណីក្រោយនេះ កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមាន ចំពោះប្រទេសនោះតាមកាលបរិច្ឆេទដែលបានកំណត់ ។

៤- ការផ្តល់សច្ចាប័ន ឬការចូលជាសមាជិក ត្រូវយល់ព្រមទទួលយកជាស្វ័យប្រវត្តិនូវរាល់ខទាំងអស់ និងការទទួលស្គាល់ចំពោះគ្រប់សារប្រយោជន៍ទាំងអស់នៃកិច្ចព្រមព្រៀងនេះ ។

## មាត្រា១០
## អានុពល និងរយៈពេលនៃកិច្ចព្រមព្រៀង

កិច្ចព្រមព្រៀងនេះ ត្រូវមានអានុភាពនិងរយៈពេលដូចគ្នាទៅនឹងអនុសញ្ញាទីក្រុងប៉ារីសស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម ។

## មាត្រា១១
## ការកែប្រែមាត្រា១ ដល់មាត្រា៤ និង មាត្រា៩ ដល់មាត្រា១៥

១- មាត្រា១ ដល់មាត្រា៤ និង មាត្រា៩ ដល់មាត្រា១៥ នៃកិច្ចព្រមព្រៀងនេះអាចដាក់ឱ្យកែប្រែដើម្បីធ្វើឱ្យកាន់តែមានភាពប្រសើរឡើង ។

២- រាល់ការកែប្រែ ត្រូវលើកយកមកពិចារណានៅក្នុងសន្និសីទដែលបានធ្វើឡើងក្នុងចំណោមប្រតិភូរបស់ប្រទេសទាំងឡាយនៃសហភាពពិសេស ។

## មាត្រា១២
## ការប្រកាសដកខ្លួនចេញ

១- ប្រទេសណាមួយ អាចប្រកាសដកខ្លួនចេញពីកិច្ចព្រមព្រៀងនេះដោយធ្វើសេចក្តីជូនដំណឹងជូនទៅអគ្គនាយក។ ការប្រកាសដកខ្លួនចេញនេះមានអានុភាពតែចំពោះប្រទេសដែលបានធ្វើការប្រកាសដកខ្លួនចេញតែប៉ុណ្ណោះ ។ កិច្ចព្រមព្រៀនេះ នៅតែមានអានុភាពអនុវត្តពេញលេញចំពោះប្រទេសផ្សេងទៀតនៃសហភាពពិសេស ។

២- ការប្រកាសដកខ្លួនចេញត្រូវមានអានុភាពក្នុងរយៈពេល១(មួយ)ឆ្នាំ បន្ទាប់ពីថ្ងៃដែលអគ្គនាយកបានទទួលសេចក្តីជូនដំណឹង ។

៣- សិទ្ធិក្នុងការប្រកាសដកខ្លួនចេញដែលមានចែងក្នុងមាត្រានេះ មិនត្រូវអនុវត្តដោយប្រទេសណាមួយមុនផុតកំណត់រយៈពេល៥(ប្រាំ)ឆ្នាំ ចាប់ពីកាលបរិច្ឆេទដែលប្រទេសនោះក្លាយជាសមាជិកនៃសហភាពពិសេស ។

## មាត្រា១៣
## ដែនដី

បទប្បញ្ញត្តិនៃមាត្រា២៤ នៃអនុសញ្ញាទីក្រុងប៉ារីសស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម ត្រូវយកមកអនុវត្តចំពោះកិច្ចព្រមព្រៀងនេះ ។

## មាត្រា១៤
## ហត្ថលេខា ភាសា សេចក្តីជូនដំណឹង

១-

ក- កិច្ចព្រមព្រៀងនេះត្រូវចុះហត្ថលេខាជាឯកសារតែមួយ ជាភាសាអង់គ្លេស និងភាសាបារាំង ដែលអត្ថបទទាំងពីរនេះមានយថាភាពដូចគ្នា និងត្រូវតម្កល់ជូនរដ្ឋាភិបាលនៃប្រទេសស្វីស ។

ខ- កិច្ចព្រមព្រៀងនេះនៅតែបើកចំហសម្រាប់ការចុះហត្ថលេខា នៅទីក្រុងប៊ែន រហូតដល់ថ្ងៃទី៣០ មិថុនា ឆ្នាំ១៩៦៩ ។

២- អត្ថបទផ្លូវការនានានឹងត្រូវធ្វើឡើងដោយអគ្គនាយក បន្ទាប់ពីពិភាក្សាជាមួយនឹងរដ្ឋាភិបាលដែលពាក់ព័ន្ធ ជាភាសាផ្សេងៗទៀតដែលសន្និបាតអាចកំណត់ ។

៣- អគ្គនាយក ត្រូវបញ្ជូនច្បាប់ចម្លងពីរច្បាប់នៃអត្ថបទដែលបានចុះហត្ថលេខានៃកិច្ចព្រមព្រៀងនេះ ដែលបញ្ជាក់ថាត្រឹមត្រូវដោយរដ្ឋាភិបាលប្រទេសស្វីស ទៅរដ្ឋាភិបាលនៃប្រទេសទាំងឡាយដែលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ និងទៅរដ្ឋាភិបាលនៃប្រទេសផ្សេងទៀតតាមការស្នើសុំ ។

៤- អគ្គនាយកត្រូវចុះបញ្ជីកិច្ចព្រមព្រៀងនេះ នៅលេខាធិការដ្ឋាននៃអង្គការសហប្រជាជាតិ ។

៥- អគ្គនាយកត្រូវជូនដំណឹងដល់រដ្ឋាភិបាលនៃប្រទេសទាំងអស់ ក្នុងសហភាពពិសេស អំពីកាលបរិច្ឆេទចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ការចុះហត្ថលេខា ការតម្កល់លិខិតតុប ករណ៍នៃការផ្តល់សច្ចាប័នឬការចូលជាសមាជិក ការយល់ព្រមលើវិសោធនកម្មចំពោះកិច្ចព្រមព្រៀងនេះ និងកាលបរិច្ឆេទដែលវិសោធនកម្មនេះចូលជាធរមាន និងសេចក្តីជូនដំណឹងអំពីការប្រកាសដកខ្លួនចេញ ។

## មាត្រា១៥
## អន្តរប្បញ្ញត្តិ

រហូតដល់អគ្គនាយកដំបូងចូលកាន់តំណែង ការយោងក្នុងកិច្ចព្រមព្រៀងនេះ ដល់ការិយាល័យអន្តរជាតិនៃអង្គការឬដល់អគ្គនាយក ត្រូវចាត់ទុកថា ជាការយោងដល់ការិយាល័យអន្តរជាតិរួមស្តីពីកិច្ចការពារកម្មសិទ្ធិបញ្ញា(BIRPI) ឬនាយកការិយាល័យ តាមករណីនីមួយៗ ។